# Transparency International Cambodia

# Sample Based Observation Frequently Asked Questions

## 2017 Commune Council Elections

**1. What is Transparency International Cambodia?**

Transparency International Cambodia (TI-C) is an official Chapter of Transparency International with a mission to work together with individuals and institutions at all levels to promote integrity and reduce corruption in Cambodia. TI-C will observe the elections to increase transparency and accountability during the election process and to deter and report irregularities and political corruption on the Election Day. The election observations will be conducted according to the strict the principles of impartiality and accuracy. TI-C is a member of the Global Network of Domestic Election Monitors and an endorser of the UN-supported Declaration of Global Principles for Nonpartisan Election Monitoring.

**2. What is Sample Based Observation?**

TI Cambodia will be conducting a proven form of observation called Sample-Based Observation (SBO). SBO is election observation that uses a statistical approach. Instead of observing in every one of the more than 22,148 polling stations in Cambodia, election observers will observe the whole process of voting and counting but only in a **representative** sample. Instead of observers concentrated in one place or another, **observers are distributed proportional to the number of polling stations across the country.** This sample methodology works just like tasting a soup in a big pot: the cook only needs to taste one spoonful of the soup to know the taste if the whole soup in that pot.

SBO is known as one of the most effective methods for evaluating elections. SBO enables the election observation organization to present an accurate and comprehensive assessment of the election day process. SBO data is gathered by local observers through direct observation of the voting and counting processes in the polling station.

**3. How is SBO different from traditional election observation?**

With an SBO, observers are deployed to a random, representative sample of polling stations; thus, the findings are representative of the entire country, not just among the polling stations observed. Other traditional forms of election monitoring can offer valuable insights to specific locations or themes, data gathered from such efforts cannot be extrapolated to the nation as a whole.

**4. What is the goal of TI Cambodia's SBO Observation?**

TI Cambodia is utilizing SBO methodology to observe Cambodia's 2017 elections in order to promote free, fair, peaceful, credible and legitimate elections for all Cambodians. By providing timely, precise and representative information on the conduct of voting and counting, SBO can help deter possible manipulation and enhance the confidence of the public and political contestants in the process.

**5. What is the SBO sample size?**

The sample includes 411 polling stations located across all of Cambodia. These are sampled polling stations in every province of the country.

**6. What is a representative sample?**

A representative sample is a statistically significant sample of something you are trying to measure, whether it's a country's level of unemployment or, in this case, the quality of the voting and counting process. Representative samples form the basis of the science of statistics. They are relied on by Governments and corporations every day to measure things.

When Governments measure things like unemployment, they don't find every person who is unemployed before they announce an unemployment rate. Rather they take samples of unemployment in all areas of a country and from those they calculate the actual level of unemployment in the country. To be representative, the sample must be designed according to statistical principles – that means using appropriate statistical methodology to measure voters' behavior.

**7. What's the difference between this and surveys?**

This is not a survey. Public Surveys rely on people's opinions on the quality of the election or of how they would vote. SBO relies on facts, like the conduct and events in the polling station and the official results of voting.

**8. Does an SBO involve observers counting ballots?**

No, TI Cambodia observers do not count the ballots. Only the election officials count ballots. TI Cambodia observers observe the voting and counting process and then record the official vote count as announced by the polling station officials.

**9. How confident is TI Cambodia in the findings of the SBO methodology?**

Statistics are a powerful and proven tool to draw accurate conclusions about a larger population based on a random sample of observations. All statistics have a margin of error. This is because statistics are only able to estimate the true result. The margin of error is based in part on the sample size, but is independent of the percentage of polling stations sampled. The final margin of error for the SBO will only be known when the information is collected from polling stations, but it will be within statistically accepted standards.

The confidence level applied to SBO is 95 percent. This is very high and is accepted by statisticians around the world.

**10. Why should journalists report this?**

We believe the public has the right to know the quality of the election. We also believe it's the job of journalists to provide important and accurate information as soon as it becomes available. The SBO is not perfect, but it is extremely reliable and very accurate. Remember, no system of voting and counting votes is perfect. Some votes are always lost, weather and other factors can disrupt the polls in some places. A SBO is best way of getting the picture of what happened across the country.

**11. Where else has the SBO methodology been used?**

Domestic observer groups around the world routinely use the SBO methodology to promote electoral integrity. SBO was first used by Citizens Movement for Free Elections (NAMFREL) in the Philippines in 1986. It has since been employed to varying degrees by observer groups in numerous countries, including: Bulgaria, Cambodia, Chile, Croatia, Guyana, Indonesia, Nigeria, Madagascar, Malawi, Montenegro, Nicaragua, Panama, Peru, Sierra Leone, Uganda, Ukraine, Zambia, Zimbabwe, and Kenya.

# ឧបសម្ព័ន្ធ ៥: កម្រងសំណួរ និងចម្លើយអំពី ការសង្កេតការណ៍ការសង្កេតការណ៍ដោយផ្អែកលើសំណាកតាមបែបវិទ្យាសាស្ត្រស្ថិតិ (SBO)

ការសង្កេតការណ៍ដោយផ្អែកលើសំណាកតាមបែបវិទ្យាសាស្ត្រស្ថិតិ
ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០១៧
កម្រងសំណួរ និងចម្លើយអំពីការសង្កេតការណ៍ការសង្កេតការណ៍ដោយផ្អែកលើសំណាកតាមបែបវិទ្យាសាស្ត្រស្ថិតិ

## ១. តើអង្គការតម្លាភាពជាអ្នកណា?

អង្គការតម្លាភាពកម្ពុជា គឺជាតំណាងផ្លូវការនៃអង្គការតម្លាភាពអន្តរជាតិដែលមានបេសកកម្មរួមគ្នាជាមួយបុគ្គលនិងស្ថាប័ននៅគ្រប់កម្រិតដើម្បី លើកកម្ពស់ សុចរិតភាព តម្លាភាព គណនេយ្យភាព និងដើម្បីកាត់បន្ថយអំពើពុករលួយនៅក្នុងប្រទេសកម្ពុជា។ អង្គការតម្លាភាពកម្ពុជានឹងសង្កេតការបោះឆ្នោតដើម្បីបង្កើនតម្លាភាពនិងគណនេយ្យភាពក្នុងអំឡុងពេលដំណើរការបោះឆ្នោត ដើម្បីបង្អាក់ ឬរាយការណ៍ពីភាពមិនប្រក្រតី និងអំពើពុករលួយនយោបាយនៅលើថ្ងៃបោះឆ្នោត។ ការសង្កេតការបោះឆ្នោតនេះនឹងត្រូវធ្វើឡើងតឹងរ៉ឹងប្រកបដោយភាពមិនលំអៀង និងភាពត្រឹមត្រូវ។ អង្គការតម្លាភាពកម្ពុជា គឺជាសមាជិកនៃបណ្តាញអ្នកឃ្លាំមើលការបោះឆ្នោតជាសកលនៃការក្នុងស្រុក និងការយល់ព្រមមួយនៃការគាំទ្រដោយអង្គការសហប្រជាជាតិសេចក្តីប្រកាសជាសកលសម្រាប់ត្រួតពិនិត្យគោលការណ៍បោះឆ្នោត ដែលមិនមែនពាក់ព័ន្ធនឹងគណបក្ស។

## ២. តើការសង្កេតការណ៍តាមសំណាកគំរូជាអ្វី?

អង្គការតម្លាភាពកម្ពុជា នឹងរៀបចំទម្រង់នៃការសង្កេតការណ៍មួយដែលហៅថាការសង្កេតការណ៍ដោយផ្អែកលើសំណាកតាមបែបវិទ្យាសាស្ត្រស្ថិតិ Sample-Based Observation (SBO)។ SBO គឺជាការសង្កេតការណ៍បោះឆ្នោតដែលប្រើវិធីសាស្ត្រស្ថិតិ។ ជំនួសឱ្យការសង្កេតការណ៍នៅគ្រប់ការិយាល័យបោះឆ្នោតទាំង២២១៩៨ទូទាំងប្រទេស អ្នកសង្កេតការណ៍ SBO នឹងសង្កេតមើលដំណើរការទាំងមូលនៃការបោះឆ្នោត ទៅលើ**សំណាកគំរូ**ដែលបានជ្រើសរើស។ **ក្រុមអ្នកសង្កេតការណ៍ត្រូវបានដាក់ពង្រាយជាសមាមាត្រទៅការិយាល័យបោះឆ្នោតទូទាំងប្រទេស**។ វិធីសាស្ត្រតាមបែបសំណាក

នេះប្រៀបបានដូចជាការភ្លក្សរសជាតិស៊ុបក្នុងឆ្នាំងធំមួយអញ្ចឹង៖ ចុងភៅត្រូវការភ្លក្សរសជាតិស៊ុបតែមួយស្លាបព្រាប៉ុនណ្ណោះ ដើម្បីដឹងពីរសជាតិស៊ុបមួយឆ្នាំងធំនោះ។

ការសង្កេតការណ៍ដោយផ្អែកតាមសំណាកនេះ គឺជាវិធីសាស្រ្តមួយដ៏មានប្រសិទ្ធភាពបំផុតមួយ ក្នុងចំណោមវិធីសាស្រ្តជាច្រើន ដែលប្រើសម្រាប់ធ្វើការវាយតម្លៃលើដំណើការបោះឆ្នោត។ SBO បានជួយសម្រួលដល់អង្គការដែលធ្វើការសង្កេតការណ៍ការបោះឆ្នោត ដើម្បីពណ៌នាពីគុណភាព នាថ្ងៃបោះឆ្នោតប្រកបដោយភាពត្រឹមត្រូវ ។ ទិន្នន័យនៃការសង្កេតការណ៍ផ្អែកតាមសំណាកគំរូ ត្រូវប្រមូលពីអ្នកសង្កេតការណ៍នៅតាមមូលដ្ឋាន តាមរយៈការសង្កេតលើដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោតដោយផ្ទាល់ ។

### ៣. តើ SBO មានភាពខុសគ្នាពីការសង្កេតតាមទំលាប់បែបណា?

ជាមួយនឹងការសង្កេតការណ៍តាម SBO អ្នកអង្កេតការណ៍ត្រូវបានដាក់ពង្រាយ តាមសំណាកតំណាងនៃការិយាល័យបោះឆ្នោតដែលបានជ្រើសយកដោយចៃដន្យ ដូច្នេះការរកឃើញនេះគឺជាតំណាងនៃប្រទេសទាំងមូលមិនមែនគ្រាន់តែនៅក្នុងចំណោមការិយាល័យបោះឆ្នោតដែលបានធ្វើការសង្កេតការណ៍ប៉ុនណ្ណោះទេ។ ទម្រង់នៃការសង្កេតការណ៍តាមទំលាប់ផ្សេងទៀត អាចផ្តល់ជូននូវការយល់ដឹងក្បោះក្បាយពីដំណើរការបោះឆ្នោត ទៅលើទីតាំង ឬគោលដៅជាក់លាក់ណាមួយ។ ទិន្នន័យដែលប្រមូលបានពីរបៀបនេះ មិនអាចយកទៅវាយតម្លៃជាលក្ខណៈប្រទេសទាំងមូលបានឡើយ។

### ៤. តើអង្គការតម្លាភាពកម្ពុជាធ្វើការសង្កេតការណ៍តាម SBO ក្នុងគោលបំណងអ្វី?

អង្គការតម្លាភាពកម្ពុជា ប្រើប្រាស់វិធីសាស្រ្តរបស់ SBO ដើម្បីឃ្លាំមើលការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ឆ្នាំ២០១៧ ក្នុងប្រទេសកម្ពុជា ក្នុងគោលបំណងដើម្បីលើកកម្ពស់ការបោះឆ្នោតប្រកបដោយ យុត្តិធម៌ សន្តិវិធី ទំនុកចិត្តនិងភាពស្របច្បាប់ជូនដល់ប្រជាពលរដ្ឋទាំងអស់។ តាមរយៈការផ្តល់ព័ត៌មានទាន់ពេលវេលា ជាក់លាក់អំពីដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនេះ SBO អាចជួយ រារាំង នូវការជ្រៀតជ្រែកជាយថាហេតុ និងពង្រឹងទំនុកចិត្តដល់សាធារណៈជន និង បេក្ខជន នៅក្នុងដំណើរការនេះ។

### ៥. តើសំណាកគំរូនៃ SBO មានទំហំប៉ុណ្ណា?

សំណាកគំរូមានប្រមាណជាង ៩១១ ការិយាល័យបោះឆ្នោត ដែលមានទីតាំងស្ថិតនៅទូទាំងប្រទេស។ សំណាកគំរូនេះ គឺជាការិយាល័យតំណាងឲ្យការិយាល័យបោះឆ្នោតទាំងអស់នៅប្រទេសកម្ពុជា។

### ៦. តើតំណាងសំណាកគំរូជាអ្វី?

តំណាងសំណាកគំរូ គឺជាគំរូស្ថិតិដ៏សំខាន់មួយដែលត្រូវបានប្រើប្រាស់ដើម្បីវាស់វែងការយល់ឃើញអ្វីមួយ ដូចជាកម្រិតនៃការអត់មានការងារធ្វើក្នុងប្រទេស ឬក្នុងករណីនេះ អំពីគុណភាពនៃដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ តំណាងសំណាកគំរូ បង្កើតឲ្យមាននូវមូលដ្ឋាននៃស្ថិតិតាមបែបវិទ្យាសាស្ត្រ។ ពួកវាពឹងផ្អែកលើ ការវាស់ស្ទង់ប្រចាំថ្ងៃរបស់រដ្ឋាភិបាល និងអាជីវកម្ម។ នៅពេលដែលរដ្ឋាភិបាលវាស់វែងភាពអត់ការងារធ្វើ ពួកគេមិនមែនស្ទង់យករាល់ចំនួនអ្នកគ្មានការងារធ្វើមុនពេលដែលពួកគេបានប្រកាសអត្រាគ្មានការងារធ្វើនោះទេ។ ប៉ុន្តែពួកគេយកសំណាកគំរូនៃភាពអត់ការងារធ្វើ និងពីការគណនាកម្រិតជាក់លាក់មួយនៃភាពអត់ការងារធ្វើនៅគ្រប់តំបន់ទូទាំងប្រទេស។ ដើម្បីអាចធ្វើជាតំណាងបាន សំណាកគំរូត្រូវតែរៀបចំឡើងដោយយោងតាមគោលការណ៍ស្ថិតិនេះមានន័យថាត្រូវប្រើប្រាស់វិធីសាស្ត្រសម្រាប់រាប់ស្ថិតិដ៏សមស្របមួយដើម្បីវាស់វែងឥរិយាបថរបស់អ្នកបោះឆ្នោត។

### ៧. តើ SBO ដូចគ្នានឹងការស្ទង់មតិដែរឬទេ?

SBO មិនមែនជាការស្ទង់មតិទេ។ ការស្ទង់មតិរួមមានការសួរអ្នកបោះឆ្នោតថាគាត់បោះឆ្នោតឲ្យអ្នកណា។ អ្នកសង្កេតការរបស់អង្គការតម្លាភាពកម្ពុជាមិនសួរអ្នកបោះឆ្នោតថាគាត់បោះឆ្នោតឲ្យអ្នកណានោះទេ។ អ្នកសង្កេតការរបស់អង្គការតម្លាភាពកម្ពុជាគ្រាន់តែកត់សម្គាល់ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត រួមទាំងសន្លឹកឆ្នោតដែលបានរាប់នៅទីនោះ។

### ៨. តើ SBO តម្រូវឲ្យអ្នកសង្កេតការចូលរួមក្នុងការរាប់សន្លឹកឆ្នោតដែរឬទេ?

អ្នកសង្កេតការរបស់អង្គការតម្លាភាពកម្ពុជាមិនចូលរួមរាប់សន្លឹកឆ្នោតទេ។ មានតែមន្ត្រីត្រួតពិនិត្យការបោះឆ្នោតប៉ុណ្ណោះដែលជាអ្នកការរាប់សន្លឹកឆ្នោត។ អ្នកសង្កេតការរបស់អង្គការតម្លាភាពកម្ពុជាឃ្លាំមើលដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត បន្ទាប់មកកត់ត្រាសន្លឹកឆ្នោតផ្លូវការដែលបានរាយការណ៍ និង ប្រកាសដោយមន្ត្រីត្រួតពិនិត្យការបោះឆ្នោត។

### ៩. តើអង្គការតម្លាភាពកម្ពុជាមានទំនុកចិត្តកម្រិតណាចំពោះលទ្ធផលចេញពីវិធីសាស្ត្រនេះ?

ទិន្នន័យស្ថិតិជាឧបករណ៍យ៉ាងសំខាន់ និងមានអនុភាពបំផុតក្នុងការសន្និដ្ឋានប្រកបដោយភាពត្រឹមត្រូវដែលទទួលបានពីប្រជាពលរដ្ឋ ដោយផ្អែកលើសំណាកគំរូនៃការសង្កេតការណ៍នេះ។ រាល់ស្ថិតិទាំងអស់អាចមានកម្រិតខុសឆ្គងតិចតួច។ នេះដោយសារតែស្ថិតិ អាចប៉ាន់ស្មានតែលទ្ធផលពិតប៉ុណ្ណោះ។ កម្រិតនៃកំហុសឆ្គង ផ្អែកលើទំហំនៃសំណាកគំរូ ប៉ុន្តែវាមិនផ្អែកទៅលើភាគរយនៃសំណាកគំរូរបស់ការិយាល័យបោះឆ្នោតនោះទេ។ កម្រិតនៃកំហុសឆ្គង ចុងក្រោយរបស់ SBO នឹងត្រូវបានដឹងនៅពេលដែលព័ត៌មានទាំងអស់ត្រូវបានប្រមូលមកពីការិយាល័យបោះឆ្នោត ប៉ុន្តែកម្រិតនៃកំហុសឆ្គងនោះស្ថិតក្នុងស្តង់ដារនៃស្ថិតិមួយដែលអាចទទួលយកបាន ពីចន្លោះពីមួយទៅពីរភាគរយតែប៉ុណ្ណោះ។ កម្រិតនៃទំនុកចិត្តនៃការអនុវត្ត SBO គឺមានយ៉ាងហោចណាស់ ៩៥ ភាគរយដែលនេះជាកម្រិតខ្ពស់ និងទទួលស្គាល់ដោយ អ្នកឯកទេសផ្នែកស្ថិតិនៅជុំវិញពិភពលោក។

## ១០. ហេតុអ្វីបានជាអ្នកកាសែតគួរតែរាយការណ៍អំពីលទ្ធផលនេះ?

យើងជឿជាក់ថាសាធារណៈជនមានសិទ្ធិក្នុងការដឹងអំពីគុណភាពនៃការបោះឆ្នោតនេះ។ យើងក៏ជឿថានេះជាការងាររបស់អ្នកកាសែតក្នុងការផ្តល់ជូននូវព័ត៌មានដែលសំខាន់ និងប្រកបដោយភាពត្រឹមត្រូវភ្លាមៗ នៅពេលដែលពួកគេទទួលបានព័ត៌មានទាំងនោះ។ SBO គឺមិនមែនជាវិធីសាស្ត្រល្អឥតខ្ចោះនោះទេ ប៉ុន្តែវាពិតជាអាចឲ្យយើងជឿទុកចិត្តបាន និងធានានូវភាពត្រឹមត្រូវ។ សូមចងចាំថា គ្មានប្រព័ន្ធត្រួតពិនិត្យការបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាដែលល្អឥតខ្ចោះនោះទេ។ សន្លឹកឆ្នោតមួយចំនួនតែងតែបាត់បង់ កត្តាអាកាសធាតុ ឬកត្តាផ្សេងៗ ទៀតអាចរំខានដល់ការិយាល័យបោះឆ្នោតនៅកន្លែងមួយចំនួន។ SBO គឺជាវិធីសាស្ត្រមួយដ៏ល្អបំផុតដើម្បីទទួលបានព័ត៌មានពីស្ថានភាពនៃការបោះឆ្នោតដែលកើតឡើងនៅទូទាំងប្រទេស។

## ១១. តើវិធីសាស្ត្រនេះត្រូវបានប្រើប្រាស់នៅកន្លែងណាទៀត?

ក្រុមអ្នកសង្កេតការក្នុងស្រុក នៅទូទាំងពិភពលោក តែងតែប្រើប្រាស់វិធីសាស្ត្រនេះ ដើម្បីលើកកំពស់សុចរិតភាពក្នុងការបោះឆ្នោត។ SBO ត្រូវបានប្រើប្រាស់ជាលើកដំបូងដោយចលនាប្រជាពលរដ្ឋដើម្បីការបោះឆ្នោតដោយសេរី (NAMFREL) នៅក្នុងប្រទេសហ្វីលីពីននៅឆ្នាំ ១៩៨៦។ វាត្រូវបានប្រើប្រាស់ដោយក្រុមអ្នកសង្កេតការផ្សេងៗទៀតនៅប្រទេសជាច្រើនរួមមាន: ប៊ុលហ្គារី ,ឈីលី, ក្រូអាដឈី, ហ្គាយ៉ាណា, ឥណ្ឌូនេស៊ី, នីហ្សេរីយ៉ា, ម៉ាដាហ្គាស្ការ, ម៉ាឡាវី, ម៉ុងទេនេក្រូ, នីការ៉ាហ្គ័រ, ប៉ាណាម៉ា, ប៉េរូ, សេរ៉ាឡេអូន, អ៊ូហ្គាន់ដា, អ៊ុយក្រែន, ហ្សាមបៀ, ហ្ស៊ីមបាវ៉េ និង ប្រទេសកេនយ៉ា ។